01585261

E462

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 09 / 2018
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ៖ | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ៖ | ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមនៅក្នុងសំណុំរឿង ០០២/០២

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

**អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២-១៩-០៩-២០០៧/អ.វ.ត.ក./អ.ជ.ស.ដ. អនុលោមតាម សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ.) ឯកសារ D427/4/15 ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ.) ឯកសារ D427/2/15 និងឯកសារ D427/3/15 ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ និងសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ.) ឯកសារ D427/1/30 ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១។

**រំលឹកឡើងវិញ** នូវការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលបិទបញ្ចប់សវនាការកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ថា អង្គជំនុំជម្រះនឹងជូនដំណឹងទៅដល់ភាគីនានា និងសាធារណជនអំពីកាលបរិច្ឆេទនៃការប្រកាសសាលក្រម នៅក្នុងពេលវេលាមួយសមស្រប[1]។

**អនុលោមតាម** វិធាន ៩៨ នៃវិធានផ្ទៃក្នុង។

**ហេតុដូច្នេះ**

**ជូនដំណឹង** ដល់ភាគីនានាថា អនុលោមតាមវិធាន ១០២(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងប្រកាសសេចក្ដីសង្ខេបសំអាងហេតុ និងផ្នែកសម្រេចសេចក្ដីនៃសាលក្រមក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅ**ថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨** នៅក្នុងសាលសវនាការធំនៃ អ.វ.ត.ក. ចាប់ពីម៉ោង ០៩:៣០ ព្រឹក។

**ជូនដំណឹង** ដល់ភាគីនានាថា អង្គជំនុំជម្រះនឹងជូនដំណឹងអំពីសំអាងហេតុពេញលេញនៃសាលក្រមនេះ នៅក្នុងពេលវេលាមួយសមស្រប។

---

[1] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ (សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល) ឯកសារ E1/528.1 ទំព័រ ២៩។

01585263

E462

**បង្គាប់ថា** ដីកានេះនឹងត្រូវជូនដំណឹងដល់ភាគីនានា និងការិយាល័យរដ្ឋបាល ព្រមទាំងត្រូវផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក.។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**